**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

*******

# កិច្ចព្រមព្រៀង

## រវាង

## រោងចក្រ ជេ-គូវី បេស (ខេមបូឌា) ឯ.ក

## ជាមួយតំណាងកម្មករនិយោជិតទាំងអស់

នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង៨ និង ០០នាទី នៅក្នុងរោងចក្រ ជេ-គូវី បេស (ខេមបូឌា) ឯក មានកិច្ចប្រជុំមួយរវាងប្រធានរដ្ឋបាល និងតំណាងកម្មករនិយោជិត និងកម្មករនិយោជិតចំនួន៣៤នាក់។ នៅក្នុងអង្គប្រជុំនេះ ប្រធានរដ្ឋបាលបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ ស្តីពីស្ថានភាពបច្ចុប្បន្ននៃការរីករាលដាលជំងឺកូវីដ-១៩ ដែលនាំឲ្យរងផលប៉ះពាល់ជាសកល លើគ្រប់វិស័យ ជាពិសេសនៅតាមរោងចក្រ សហគ្រាស បណ្តាលឲ្យខ្វះខាតទំនិញសម្រាប់ផ្គត់ផ្គង់ខ្សែសង្វាក់ផលិតកម្មនៅតាមផ្នែកផ្សេងៗក្នុងរោងចក្រ។ ហេតុដូចនេះរោងចក្រសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន៣៤នាក់ (ស្រី ២១នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ៨៤នាក់ (ស្រី ៤៥នាក់) រយៈពេល ២០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ កម្មករនិយោជិតទទួលបានអត្ថប្រយោជន៍ និងការទូទាត់ដូចតទៅ៖

-ប្រាក់ឧបត្ថម្ភពីរោងចក្រ ចំនួន២០ដុល្លារអាមេរិក បើកជូននៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ ។

-ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ចំនួន៣០ដុល្លាអាមេរិក តាមរយៈភ្នាក់ងារវីង។

ចំពោះការព្យួរកិច្ចសន្យាការងារនេះ យោងតាមសេចក្តីណែនាំ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង៨ និង ៤៥នាទី ព្រឹកថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**នាយកក្រុមហ៊ុន**

KIM HWI SUN

**ស្នាមមេដៃតំណាងកម្មករនិយោជិតទាំងអស់**